**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គនាយកដ្ឋានពន្ធដារ**

លេខ......១៥១.........អពដ

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មករា ឆ្នាំ២០១៤

# សេចក្តីណែនាំ
## អំពីការកំណត់ចំណាយការប្រាក់របស់សហគ្រាស

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១១ និងមាត្រា១២ នៃច្បាប់ស្តីពីសារពើពន្ធ ផ្នែកទី៥.៩ និងផ្នែកទី៨.១ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញលេខ១០៥៩ ប្រក.សហវ.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ និងយោងតាមការសម្រេចរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២០ខែមករា ឆ្នាំ២០១២ លើលិខិតរបស់អគ្គនាយកដ្ឋានពន្ធដារ លេខ ១៣០៤ អពដ ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១ ដើម្បីឱ្យមានសង្គតិភាពក្នុងការកំណត់ចំណាយការប្រាក់ដែលអាចកាត់កងបាន អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំដល់គ្រប់អង្គភាពពន្ធដារ និងគ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដូចតទៅ ÷

១- ចំពោះសហគ្រាសដែលបានកត់ត្រាក្នុងតារាងតុល្យការនូវប្រាក់ខ្ចី (Loan) ដែលបានខ្ចីពីធនាគារ ឬស្ថាប័នសញ្ញ័យធន ឬខ្ចីពីសហគ្រាសដទៃ ប៉ុន្តែគ្មានការកត់ត្រាចំណាយការប្រាក់ អង្គភាពពន្ធដារត្រូវអនុវត្តដូចខាងក្រោម ÷

ក- មិនត្រូវបង្កើត "ចំណាយការប្រាក់ដោយសន្មត (Deemed Interest Expense)" ដើម្បីគោលដៅនៃការកំណត់ពន្ធកាត់ទុកលើសហគ្រាសទេ ស្របតាមផ្នែកទី៨.១.២ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញដែលបានចែងថា " សម្រាប់គោលដៅនៃពន្ធកាត់ទុក ចំណាយណាមួយដែលជាកម្មវត្ថុនៃពន្ធកាត់ទុកដែលបានកត់ត្រាជាចំណាយក្នុងបញ្ជីគណនេយ្យ ត្រូវចាត់ទុកថាបានទូទាត់ "។ ដូច្នេះបើសហគ្រាសមិនបានកត់ត្រាចំណាយណាមួយក្នុងបញ្ជីគណនេយ្យ ចំណាយនោះមិនត្រូវចាត់ទុកថាបានទូទាត់ និងមិនមែនជាកម្មវត្ថុនៃពន្ធកាត់ទុកទេ។

ខ- មិនត្រូវបង្កើត "ចំណូលពីឧបត្ថម្ភធនដោយសន្មត (Deemed Subsidy)" ដើម្បីគោលដៅនៃការកំណត់ប្រាក់ចំណូលជាប់ពន្ធលើប្រាក់ចំណេញចំពោះសហគ្រាសឡើយ ។

២- ចំពោះសហគ្រាសដែលបានកត់ត្រាក្នុងតារាងតុល្យការនូវប្រាក់ខ្ចី (Loan) ដែលបានខ្ចីពីធនាគារ ឬស្ថាប័នសញ្ញ័យធន ឬខ្ចីពីសហគ្រាសដទៃ ដោយមានការប្រាក់ទាបជាងកម្រិតការប្រាក់ទីផ្សារ អង្គភាពពន្ធដារមិនត្រូវបង្កើតចំណាយការប្រាក់ដោយសន្មត ដើម្បីកំណត់ពន្ធកាត់ទុក ឬបង្កើតចំណូលពីការឧបត្ថម្ភធនដោយសន្មតដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធលើចំណែកនៃការប្រាក់ដែលទាបជាងកម្រិតការប្រាក់ទីផ្សារឡើយ។

៣- ចំពោះសហគ្រាសដែលបានកត់ត្រាក្នុងតារាងតុល្យការនូវប្រាក់ខ្ចី (Loan) ដែលបានខ្ចីពីធនាគារ ឬស្ថាប័នសញ្ញ័យធន ឬខ្ចីពីសហគ្រាសដទៃទៀត ដោយមានការប្រាក់ខ្ពស់ជាងកម្រិតការប្រាក់ទីផ្សារ អង្គភាពពន្ធដារត្រូវ ÷

ក- ក្នុងករណីសហគ្រាសខ្ចីប្រាក់ពីបុគ្គលដែលមិនមែនជាបុគ្គលជាប់ទាក់ទិន កម្រិតការប្រាក់ដែលត្រូវអនុញ្ញាត មិនត្រូវឱ្យលើសពី ១២០ ភាគរយ នៃកម្រិតអត្រាការប្រាក់ទីផ្សារនៅពេលខ្ចីប្រាក់។

ខ- ក្នុងករណីសហគ្រាសខ្ចីប្រាក់ពីបុគ្គលជាប់ទាក់ទិន ទឹកប្រាក់ចំណាយការប្រាក់មិនត្រូវឱ្យលើសពីកម្រិតអត្រាការប្រាក់ទីផ្សារនៅពេលខ្ចីប្រាក់។

សម្រាប់គោលដៅនៃសេចក្តីណែនាំនេះ កម្រិតអត្រាការប្រាក់ទីផ្សារគឺជាមធ្យមភាគនៃអត្រាការប្រាក់ឱ្យខ្ចីរបស់ធនាគារពាណិជ្ជធំៗក្នុងស្រុកយ៉ាងតិច ៥ ដែលចេញជារៀងរាល់ឆ្នាំដោយអគ្គនាយកដ្ឋានពន្ធដារ។

៤- ចំណាយការប្រាក់ដូចមានចែងក្នុងចំណុចទី២ និងចំណុចទី៣នៃសេចក្តីណែនាំនេះ ត្រូវបានអនុញ្ញាតឱ្យកាត់កងបន្ទាប់ពីបានអនុវត្តកំហិតនៃការកាត់កងចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធតាមមាត្រា១២ នៃច្បាប់ស្តីពីសារពើពន្ធ និងផ្នែកទី៥.៩ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ។

៥- រាល់ការខ្ចីប្រាក់ដូចបានបរិយាយក្នុងចំណុចទី១ ទី២ និងទី៣ខាងលើ សហគ្រាសត្រូវជូនដំណឹងមករដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមរយៈពេល៣០ថ្ងៃ ក្រោយប្រតិបត្តិការខ្ចីបុលបានកើតឡើងដោយភ្ជាប់ជាមួយនូវកិច្ចសន្យាឬកិច្ចព្រមព្រៀងឬឯកសារដែលបញ្ជាក់ច្បាស់លាស់ពីការខ្ចីប្រាក់។ ក្នុងករណីដែលសហគ្រាសមិនបានជូនដំណឹងមករដ្ឋបាលសារពើពន្ធ និងគ្មានឯកសារបញ្ជាក់សមស្រប ប្រាក់ខ្ចីត្រូវបានចាត់ទុកថាជាប្រាក់ខ្ចីគ្មានភស្តុតាងបញ្ជាក់ ដែលនាំឱ្យកើនឡើងនូវទ្រព្យសកម្មពិត និងត្រូវគិតបញ្ចូលជាប្រាក់ចំណេញជាប់ពន្ធស្របតាមខ្លឹមសារនៃផ្នែកទី២.២.៣.ច នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ។

សេចក្តីណែនាំនេះជំនួសឱ្យសេចក្តីណែនាំអំពីការកំណត់ពន្ធចំពោះ ប្រាក់ខ្ចីគ្មានការប្រាក់ ឬការប្រាក់ទាបជាង ឬខ្ពស់ជាងកម្រិតការប្រាក់ទីផ្សារ លេខ ១៧០៧ អពដ. ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៣។ គ្រប់អង្គភាពពន្ធដារ និងគ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**ចម្លងជូន** :
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពពន្ធដារ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ